# អង្គជំនុំជម្រះសាលាដំបូងសម្រេចថា អៀង សារី មានសម្បទាគ្រប់គ្រាន់ និងអាចតាមដានសវនាការបានតាមរយៈប្រព័ន្ធសោតទស្សន៍

អែន ហេនឌែលៈ ទីប្រឹក្សាផ្នែកច្បាប់នៃមជ្ឈមណ្ឌលឯកសារកម្ពុជា

៣០ វិច្ឆិកា ២០១២

ប្រែសម្រួលដោយ ឌី សុជាតា

មានការព្រួយបារម្ភចំពោះវ័យចំណាស់និងសុខភាពកាន់តែផុយស្រួយរបស់ជនជាប់ចោទ ដែលជាអតីតមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមនិងដែលបច្ចុប្បន្នកំពុងទទួលការជំនុំជម្រះនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ថាពុំអាចរស់រានមានជីវិតរហូតដល់ពេលចេញសាលក្រម ។ ជាក់ស្តែងជនជាប់ចោទម្នាក់ត្រូវបានរកឃើញថា ពុំមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ និងត្រូវបានដកចេញពីសំណុំរឿង ។ ក្នុងវ័យ៨៧ឆ្នាំ ជនជាប់ចោទ អៀង សារី មានកាយសម្បទាទន់ខ្សោយពិបាកក្នុងការផ្តោតអារម្មណ៍រយៈពេលវែង និងពុំអាចអង្គុយតាមដានសវនាការពេញមួយថ្ងៃបាន ដូច្នេះ អៀង សារី ជាទូទៅតែងតែបង្ហាញខ្លួននៅពេលចាប់ផ្តើមសវនាការ ។ បន្ទាប់ពីសម្រាក សវនាការពេលព្រឹក អៀង សារី តែងតែដាក់សំណើសុំទៅតាមដានសវនាការពីចម្ងាយនៅក្នុងបន្ទប់ ដែលមានបំពាក់ប្រព័ន្ធសោតទស្សន៍ បើទោះបីជាសវនាការនឹងបន្តរហូតដល់ម៉ោង៤រសៀលក៏ដោយ ។ ការពិនិត្យតាមបែបវេជ្ជសាស្ត្រដល់ អៀង សារី បានធ្វើឲ្យមានការផ្អាកសវនាការរហូតដល់១២ថ្ងៃ ។ បន្ទាប់វិលត្រឡប់ពីការព្យាបាលអស់រយៈពេល៣ខែនៅមន្ទីរពេទ្យ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា អៀង សារី មានសម្បទាគ្រប់គ្រាន់ ព្រមទាំងបានសម្រេចថា ដើម្បីសម្រាលដល់ការបន្តវិវត្តទៅមុខនៃសុខភាពរបស់ជនជាប់ចោទឲ្យមានប្រសិទ្ធភាព អៀង សារី គប្បីលះបង់សិទ្ធិមានវត្តមាននៅក្នុងបន្ទប់សវនាការ ប៉ុន្តែត្រូវចូលរួមសវនាការ តាមរយៈសោតទស្សន៍ពីបន្ទប់ឃុំឃាំង ។ តុលាការអន្តរជាតិមុនៗ ធ្លាប់ទាមទារឲ្យជនជាប់ចោទចូលរួមក្នុងដំណើរការនីតិវិធីតាម រយៈប្រព័ន្ធសោតទស្សន៍ដែរ ប៉ុន្តែករណីបែបនេះនៅពុំទាន់បានកើតឡើងនៅឡើយទេ ពីព្រោះតុលាការទាំងនោះយល់ឃើញថាការធ្វើបែបនេះគឺមិនទាន់សមស្របនៅឡើយ ។

នៅឆ្នាំ២០១១ ក្រុមមេធាវីការពារក្តី អៀង សារី បានទាមទារឲ្យបើកសវនាការកន្លះថ្ងៃ ដោយលើកហេតុផលថា អៀង សារី "មានសិទ្ធិមានវត្តមាន និងមានបំណងអនុវត្តសិទ្ធិនេះ ប៉ុន្តែអាយុនិងសុខភាពរារាំង អៀង សារី មិនឲ្យអង្គុយនៅក្នុងបន្ទប់សវនាការក្នុងរយៈពេលយូរបានឡើយ" ។ ក្រុមមេធាវីការពារក៏ពុំបានជំទាសនឹងការរកឃើញរបស់អ្នកជំនាញផ្នែកមនុស្សចាស់ ដែលថាសុខភាព

របស់ អៀង សារី ពុំប៉ះពាល់អ្វីដល់កាយសម្បទាក្នុងការចូលរួមសវនាការនោះឡើយ ។ ក្រោយមក តុលាការបានកែប្រែវិធានផ្ទៃក្នុងរបស់ខ្លួន ដោយតម្រូវឲ្យជនជាប់ចោទចូលរួមសវនាកាពីចម្ងាយ និង មិនចាំបាច់មានការយល់ព្រមពីជនជាប់ចោទ "ប្រសិនជនជាប់ចោទអវត្តមាន នៅកម្រិតដែលបណ្តាល ឲ្យពន្យាពេលសវនាការយូរ និងប៉ះពាល់ដល់ផលប្រយោជន៍យុត្តិធម៌" ។

អង្គជំនុំជម្រះសាលាដំបូងផ្អាកដំណើរការនីតិវិធីជាបណ្តោះអាសន្ននៅ ពេល អៀង សារី មានជម្ងឺធ្ងន់ធ្ងរពុំអាចចូលរួមសវនាការបាន ។ ប៉ុន្តែថ្មីៗនេះ នៅអំឡុងពេលទទួលការព្យាបាល ក្នុងមន្ទីរ ពេទ្យរយៈពេលបីខែថ្មីៗនេះ អៀង សារី បានលះបង់សិទ្ធិមានវត្តមាននៅក្នុងសវនាការស្តាប់សក្ខីកម្ម សាក្សីមួយចំនួនដែលគាត់មិនបានរំពឹងទុក ហើយដែលនឹងផ្តល់សក្ខីកម្មអំពីការប្រព្រឹត្ត និងឧក្រិដ្ឋកម្ម ដែលជាប់ពាក់ព័ន្ធនឹង អៀង សារី ។ នាពេលបច្ចុប្បន្ន ជនជាប់ចោទ អៀង សារី បានវិលត្រឡប់ មកកាន់មន្ទីរឃុំឃាំងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ហើយក្រុមមេធាវី ការពារក្តីបាន លើកឡើងថា អៀង សារី ពុំមានសម្បទាគ្រប់គ្រាន់ក្នុងការតាមដានកិច្ចដំណើរការនីតិវិធី ហើយ អៀង សារី នៅរក្សាជំហរមិនស្តាប់សក្ខីកម្មរបស់សាក្សីដែលមិនសូវមានឥទ្ធិពលលើសំណុំរឿង របស់ខ្លួន ។ មេធាវីការពារក្តីរំពឹងទុកថា សុខភាពកូនក្តីរបស់ខ្លួននឹងបានប្រសើរឡើងវិញ ។ ប៉ុន្តែ មេធាវីការពារក្តី លើកឡើងថា ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងសម្រេចថា អៀង សារី មាន សម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ មេធាវីនឹងការណែនាំឲ្យ អៀង សារី បោះបង់ចោល នូវការបដិសេធរបស់ខ្លួន ព្រមទាំងស្វែងរកភ្លាមនូវការបំបែកកិច្ចដំណើរការនីតិវិធីរបស់ អៀង សារី ។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក៏ដូចជាតុលាការអន្តរជាតិត្រូវធានាសិទ្ធិរបស់ជនជាប់ ចោទក្នុងការទទួលបាន "ការជំនុំជម្រះត្រូវតែមានវត្តមានរបស់ជនជាប់ចោទ" ។ ដើម្បីជួយសម្រួល ដល់ការចូលរួមរបស់ជនជាប់ចោទដែលមានវ័យចំណាស់ អង្គជំនុំជម្រះបានរៀបចំបន្ទប់ពិសេសមួយ ដែលអនុញ្ញាតឲ្យជនជាប់ចោទអាចតាមដានកិច្ចដំណើរការនីតិវិធីនៅក្នុងសវនាការ និងអាចឲ្យជនជាប់ ចោទ ចង្អុលបង្ហាញមេធាវីរបស់ខ្លួនតាមរយៈប្រព័ន្ធសម្លេង និងរូបភាព ។ ក្រុមមេធាវីការពារក្តី អៀង សារី បានលើកឡើងថា "ប្រព័ន្ធបច្ចេកវិទ្យាសោតទស្សន៍មិនដូចគ្នានឹងវត្តមានដោយផ្ទាល់របស់ជន ជាប់ ចោទនៅក្នុងសវនាការនោះឡើយ" ។ ដើម្បីបកស្រាយ មេធាវីការពារក្តីបានលើកយកយុត្តិសាស្ត្រ របស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការអន្តរជាតិសម្រាប់ប្រទេស រ៉្វាន់ដា (ICTR) ដែលបាន បញ្ជាក់ថា "សិទ្ធិក្នុងការទទួលបានការជំនុំជម្រះដោយមានវត្តមានរបស់ជនជាប់ចោទ គឺសំដៅទៅលើ វត្តមានជារូបវន្តរបស់ជនជាប់ចោទនៅក្នុងសវនាការ" ។ ហើយវិធាននៅតុលាការព្រហ្មទណ្ឌ អន្តរជាតិ សម្រាប់ប្រទេសរ៉្វាន់ដា តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេស យូហ្គោស្លាវី (ICTR) តុលាការព្រហ្មទណ្ឌអន្តរជាតិ និងតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាលេអូន ពុំបានសម្រេចថា

ការចូលរួមសវនាការដោយផ្ទាល់ជារូបវន្ត និងការចូលរួមតាមរយៈប្រព័ន្ធសោតទស្សន៍ថាមានលក្ខណៈដូចគ្នាទេ ។

ប៉ុន្តែតុលាការទាំងនោះបានកំណត់ថា សិទ្ធិមានវត្តមានរបស់ជនជាប់ចោទ គឺពុំមានលក្ខណៈដាច់ខាតឡើយ ដូច្នេះវាទំនងជាអាចមានការបោះបង់ ឬបង្ខំឲ្យបោះបង់សិទ្ធិ នៅពេលដែលសិទ្ធិនោះ«បង្អាក់ដំណើរសវនាការខ្លាំង» ។ ការដាក់កម្រិតទៅលើសិទ្ធិមានវត្តមានរបស់ជនជាប់ចោទត្រូវតែវាយតម្លៃទៅតាមគោលការណ៍សមាមាត្រ ដែលអនុលោមទៅតាមលក្ខខណ្ឌស្តីពីសិទ្ធិជាមូលដ្ឋានដែលចែងថាការដាក់កំហិតទាំងឡាយទៅលើសិទ្ធិមូលដ្ឋានត្រូវតែសមស្របទៅតាមគោលការណ៍ និង សំខាន់ជាងសិទ្ធិផ្សេងទៀត ។

សហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានលើកហេតុផលថាតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងតុលាការអន្តរជាតិសម្រាប់ប្រទេសរ៉ាន់ដាពុំដូចជាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទេ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺជាតុលាការអនុវត្តច្បាប់ស៊ីវិល ដែលអនុញ្ញាតឲ្យមានសវនាការកំបាំងមុខ ។ សហព្រះរាជអាជ្ញា បានកត់សម្គាល់ថានៅក្នុងតុលាការពិសេសសម្រាប់ប្រទេសលីបង់ដែលផ្អែកលើច្បាប់ស៊ីវិល ពាក្យថា «វត្តមានរបស់ជនជាប់ចោទ» ពុំបានកំណត់ច្បាស់លាស់ថាត្រូវតែជា «វត្តមានផ្នែករូបកាយរបស់ជនជាប់ចោទទេ» វាអាចរួមបញ្ចូលទាំង «វត្តមានរបស់ជនជាប់ចោទតាមផ្លូវច្បាប់» ។ លើសពីនេះទៀត សហព្រះរាជអាជ្ញាបានសង្កត់ធ្ងន់ថា នៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីត ប្រទេសយូហ្គោស្លាវី និងតុលាការអន្តរជាតិសម្រាប់ប្រទេសរ៉ាន់ដា តាម«គោលការណ៍សមាមាត្រ» សវនាការអាចបន្តដោយអវត្តមានជនជាប់ចោទ នៅពេលដែលជនជាប់ចោទបង្អាក់ការសវនាការរយៈពេលយូរបើទោះបីជានោះជាការបង្អាក់អចេតនាក៏ដោយ ។

អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានសម្រេចថា អៀង សារី មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ ហើយច្រានចោលសំណើររបស់ក្រុម មេធាវីការពារក្តីដែលស្នើឲ្យបន្ថែមអ្នកជំនាញដើម្បីពិនិត្យសុខភាពរបស់ អៀង សារី និងធ្វើកំណត់សម្គាល់ថាការចូលរួមសវនាការរបស់ អៀង សារី នៅក្នុងបន្ទប់ឃុំឃាំង ដែលមានបំពាក់ប្រព័ន្ធសោតទស្សន៍និងមានកន្លែងសម្រាប់ទម្រេតខ្លួនបាន អាចសម្រួលដល់បញ្ហាប្រឈមចំពោះការចូលរួមក្នុងសវនាការ ។ អង្គជំនុំជម្រះសាលាដំបូង ក៏បានច្រានចោលសំណើររបស់ក្រុមមេធាវីការពារក្តីដែលចង់ថត អៀង សារី « នៅក្នុងបន្ទប់ឃុំខ្លួនដែលមានភ្ជាប់ប្រព័ន្ធសោតទស្សន៍ ឬនៅក្នុងសាលសវនាការ ដែលអាចឲ្យតុលាការ និងសាធារណៈជនអាចតាមដាន និងវាយតម្លៃការចូលរួមដ៏មានអត្ថន័យរបស់ អៀង សារី» ។ ប៉ុន្តែ អង្គជំនុំជម្រះសាលាដំបូងបានកំណត់ថា ការបង្គាប់ឲ្យ អៀង សារី ចូលរួមសវនាការ

ពីបន្ទប់ដែលមានភ្ជាប់ប្រព័ន្ធសោតទស្សន៍ "គឺដើម្បីបម្រើនូវផលប្រយោជន៍យុត្តិធម៌ … មិនចាំបាច់ប្រើប្រាស់ហេតុផលផ្នែកវេជ្ជសាស្ត្រដើម្បីបកស្រាយពីអវត្តមានរបស់ជនជាប់ចោទក្នុងការចូលរួមកិច្ចដំណើរការនីតិវិធី ។ ការធ្វើបែបនោះអាចប៉ះពាល់ដល់ផលប្រយោជន៍ផ្នែកវេជ្ជសាស្ត្រ ប៉ុន្តែដើម្បីពន្លឿនកិច្ចដំណើរការនីតិវិធី" ។ អង្គជំនុំជម្រះ សាលាដំបូងបានរកឃើញថា ការថតជាវីដេអូ "គឺពុំមានភាពចាំបាច់ក្នុងការធានាថាជនជាប់ចោទទទួលការតាមដានបានត្រឹមត្រូវនោះទេ" ។

នៅក្នុងរឿងក្ដី Stanisic & Simatovic នៅអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី បានជួបប្រទះនឹងបញ្ហាស្រដៀងគ្នាទាក់ទងនឹងការការពារក្ដី ហើយបានពិចារណាថាតើអង្គជំនុំជម្រះសាលាដំបូងបាន "បំពានទៅលើការប្រើប្រាស់ឆន្ទានុសិទ្ធរបស់ខ្លួនឲ្យបង្កើតនូវប្រព័ន្ធសោតទស្សន៍ដើម្បីអនុញ្ញាតឲ្យជនជាប់ចោទអាចចូលរួមនៅក្នុង ដំណើរការនីតិវិធីពីបន្ទប់ឃុំឃាំងនៅក្នុងថ្ងៃណាដែលជនជាប់ចោទមានស្ថានភាពសុខភាពពុំសូវល្អ" ដែរបទេ ។អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានរកឃើញថាបើទោះបីជាអង្គជំនុំជម្រះសាលាដំបូងបានថ្លឹងថ្លែងនូវ សិទ្ធិរបស់ជនជាប់ចោទ និងសិទ្ធផ្សេងៗទៀតដើម្បីពន្លឿនកិច្ចដំណើរការនីតិវិធីអង្គជំនុំជម្រះក៏ដោយ ក៏សាលាដំបូងបានខកខាន "ក្នុងការផ្ដល់នូវទម្ងន់គ្រប់គ្រាន់" ដល់សិទ្ធិមានវត្តមានក្នុងសវនាការ ហើយមិនបានពិចារណាលើជម្រើសសំខាន់ៗផ្សេងទៀតរួមទាំង "ការអនុញ្ញាតឲ្យករណីនេះស្ថិតនៅក្នុងដំណាក់កាលសវនាការបឋមសម្រាប់រយៈពេល៣ទៅ៦ខែសិន" ។ លើសពីនេះទៀត អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានសម្រេចថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសឆ្គងដោយ "ខកខាន" មិនបានពិចារណាថាតើជនជាប់ចោទមានសម្បទាផ្នែកផ្លូវកាយ និងផ្នែកបញ្ញាស្មារតីគ្រប់គ្រាន់សម្រាប់ចូលរួមសវនការតាមរយៈប្រព័ន្ធសោតទស្សន៍ ។

ចំពោះករណីថាតើអៀង សារី គួរតែលះបង់សិទ្ធិក្នុងការចូលរួមសវនាការ ហើយថាតើអង្គជំនុំជម្រះគួរតែបង្គាប់ឲ្យជនជាប់ចោទឲ្យចូលរួមសវនាការពីបន្ទប់ឃុំឃាំងដែលមានភ្ជាប់ប្រព័ន្ធសោតទស្សន៍ដែរឬទេ ក្រុមមេធាវីការពារក្ដីទំនងជានឹងអះអាងថាការផ្អាកសវនការរយៈពេល១២ថ្ងៃដោយសារតែបញ្ហាសុខភាពធ្លាក់ចុះរបស់ អៀង សារី ពុំមែនជា "ការផ្អាកសវនាការរយៈពេលយូរទេ" ដូច្នេះវាមិនឆ្លើយតបនឹងមូលដ្ឋានសមាមាត្រ ។ ហើយការធ្វើបែបនេះមិនបានពិចារណាថាតើការចូលរួមរបស់ជនជាប់ចោទពីចម្ងាយគឺមានប្រសិទ្ធភាពឬយ៉ាងណាទេ ។